ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តក្រចេះ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ......០៧.........ខ

ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩

បណ្ដឹងរឿងព្រហ្មទណ្ឌលេខ៣២៥

ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨

បណ្ដុំរឿងស៊ើបសួរលេខ២២២

ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨

បណ្ដុំរឿងជំនុំជម្រះលេខ២៨៤

ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨

# **តាងនាមប្រជារាស្ត្រខ្មែរ**
# **សាលាដំបូងខេត្តក្រចេះ**

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តក្រចេះ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ដោយមានសមាសភាពជំនុំជម្រះ ដូចខាងក្រោម:

## **ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តក្រចេះ។

## **តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តក្រចេះ។

## **ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តក្រចេះ។

## **ដើម្បីជំនុំជម្រះ**

លើបណ្ដុំរឿងព្រហ្មទណ្ឌលេខ៣២៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ:

**១**-ឈ្មោះ [redacted] **ណារ៉ាត់** ហៅ **វិត** ភេទប្រុស អាយុ ២៥ឆ្នាំ មុខរបរកសិករ ទីកន្លែងកំណើតនៅ [redacted] ខេត្តក្រចេះ។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិ [redacted] ខេត្តក្រចេះ។ ឪពុកឈ្មោះ [redacted] ណារិន "រ" ម្ដាយឈ្មោះ [redacted] ដានី "រ"។ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ១១២ "ឃខ" ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨។

ជាប់ចោទពីបទ: **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិឈើទាលភ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**២**-ឈ្មោះ [redacted] **វណ្ណនី** ហៅ **ខៅល** ភេទប្រុស អាយុ ៣៣ឆ្នាំ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តក្រចេះ។ ទីលំនៅមុនពេលឃុំខ្លួននៅភូមិ [redacted] ខេត្តក្រចេះ។ ឪពុកឈ្មោះ [redacted] ឡាំ "រ" ម្ដាយឈ្មោះ [redacted] គន្ធា "រ"។ ទោសពីមុនគ្មាន។ (ក្រៅឃុំ)។

ជាប់ចោទពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិឈើទាលភ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-មេធាវីការពារជនជាប់ចោទឈ្មោះកែវ ណារ៉ាត់ ហៅ វិត លោកឡុង បញ្ញាវុឌ្ឍ។

-**បានឃើញ** របាយការណ៍សរុបលេខ១១៩/១៨ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀន។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៣២៥ អ.យ.ក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់អយ្យការអមសាលាដំបូងខេត្តក្រចេះ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ២៣៦ អ.យ.ក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់អយ្យការអមសាលា



Scanned with CamScanner

ដំបូងខេត្តក្រចេះ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ២៣១៩ "ពស" ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ។

## អង្គហេតុនៃរឿងមានដូចតទៅ:

-កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង១៧ និង ៣០នាទី កម្លាំងសមត្ថកិច្ចបានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុ នៅភូមិឈើទាលឃ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ ដោយបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ណារ៉ាត់ ហៅ វិត ភេទប្រុស អាយុ ២៥ឆ្នាំ និងដកហូតបានគ្រឿងញៀនចំនួន០១កញ្ចប់តូច។ ក្រោយការសាកសួរ ជនជាប់ចោទឈ្មោះ [redacted] ណារ៉ាត់ ហៅ វិត បានឆ្លើយសារភាពថា ខ្លួនបានទិញគ្រឿងញៀនពីជនជាប់ចោទឈ្មោះ [redacted] វណ្ណនី ហៅ ង៉ោល ភេទប្រុស អាយុ ៣៣ឆ្នាំ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ណារ៉ាត់ ហៅ វិត បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃ០៩ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង ៥ល្ងាច ខ្លួនមិនបានលក់ដូរគ្រឿងញៀននោះទេ។ ប៉ុន្តែ ខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀនដោយខ្លួនបានទិញគ្រឿងញៀនប្រភេទម៉ាទឹកកពីឈ្មោះ [redacted] វណ្ណនី ហៅង៉ោល ដោយទិញក្នុងមួយកញ្ចប់តូចតម្លៃ២០,០០០រៀល។ ក្រោយពេលទិញគ្រឿងញៀនបានហើយខ្លួនបានយកគ្រឿងញៀននោះទៅប្រើប្រាស់នៅក្នុងព្រៃ។ ប៉ុន្តែខ្លួនមិនទាន់បានប្រើប្រាស់គ្រឿងញៀនផងក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបានគ្រឿងញៀនចំនួន១កញ្ចប់តូច។ កន្លងមកខ្លួនបានប្រើប្រាស់គ្រឿងញៀនរយៈពេល២ខែមកហើយ និងទិញគ្រឿងញៀនពីឈ្មោះ [redacted] វណ្ណនី ហៅ ង៉ោល បានចំនួន១៥ដងមកហើយ។

-ក្រឡាបញ្ជីអានដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៧៩ "ចឱ" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ លើឈ្មោះ [redacted] វណ្ណនី ហៅ ង៉ោល។

-ក្រឡាបញ្ជីអានកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនឈ្មោះ [redacted] ណារ៉ាត់ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀន។

-ក្រឡាបញ្ជីអានកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់សារធាតុញៀនឈ្មោះកែវ ណារ៉ាត់ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀន។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ១៤៧២៣/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់ឈ្មោះកែវ ណារ៉ាត់។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលចាប់យក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់មន្ត្រីនគរបាលយុត្តិធម៌។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ជនជាប់ចោទឈ្មោះ [redacted] ណារ៉ាត់ បានឆ្លើយសារភាពនូវអំពើរបស់ខ្លួនដែលចម្លើយនេះមានភាពស៊ីសង្វាក់ជាមួយភស្តុតាងនានាដែលបញ្ជាក់ថា:ជនជាប់ចោទឈ្មោះគាត វណ្ណនី ហៅង៉ោល ពិតជាបានជួញដូរគ្រឿងញៀនប្រាកដមែន។ រីឯជនជាប់ចោទឈ្មោះ [redacted] ណារ៉ាត់ ពិតជាបានរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ ដូច្នេះ តំណាងអយ្យការតម្កល់ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] វណ្ណនី ហៅ ង៉ោល និងប្តឹងសុំកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះកែវ ណារ៉ាត់ពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនមកបទរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំឱ្យតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន។

-មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ណារ៉ាត់ ហៅវិត លោក [redacted] បញ្ញាវុឌ្ឍ បានធ្វើសេចក្តីសន្និដ្ឋានការពារថា:



Scanned with CamScanner

ជនជាប់ចោទឈ្មោះ[redacted]ណាភ៉ត់ មិនបានជួញដូរគ្រឿងញៀនទេ គឺគ្រាន់តែបានប្រើប្រាស់គ្រឿងញៀនតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតការឃុំខ្លួនមានរយៈពេលយូរណាស់មកហើយ។ ដូច្នេះ ខ្លួនសុំឱ្យតុលាការសម្រេចដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពវិញ។

-ជនជាប់ចោទឈ្មោះកែវ ណាភ៉ត់ ហៅ វិត និយាយសំដីចុងក្រោយថា: សុំតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយជនជាប់ចោទ។

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តក្រចេះ

## យល់ឃើញថា

១-ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ២៣១៩ "ពស" ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ បានសម្រេចបញ្ជូនឈ្មោះកែវ ណាភ៉ត់ ហៅ វិត ភេទប្រុស អាយុ ២៥ឆ្នាំ ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងឈ្មោះ[redacted]វណ្ណនី ហៅ ម៉ោល ភេទប្រុស អាយុ ៣០ឆ្នាំ ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិឈើទាលភ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ជនជាប់ចោទឈ្មោះ[redacted] ណាភ៉ត់ ហៅ វិត បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃ០៩ ខែឧសភា ឆ្នាំ២០១៨ វេលាម៉ោង៥ល្ងាច ខ្លួនមិនបានលក់ដូរគ្រឿងញៀននោះទេ។ ប៉ុន្តែ ខ្លួនពិតជាបានប្រើប្រាស់គ្រឿងញៀនដោយខ្លួនបានទិញគ្រឿងញៀនប្រភេទម៉ាទឹកកកពីឈ្មោះ[redacted]វណ្ណនី ហៅម៉ោល ដោយទិញក្នុងមួយកញ្ចប់តូចតម្លៃ២០,០០០រៀល។ ក្រោយពេលទិញគ្រឿងញៀនបានហើយខ្លួនបានយកគ្រឿងញៀននោះទៅប្រើប្រាស់នៅក្នុងព្រៃ។ ប៉ុន្តែខ្លួនមិនទាន់បានប្រើប្រាស់គ្រឿងញៀនផងក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបានគ្រឿងញៀនចំនួន១កញ្ចប់តូច។ កន្លងមកខ្លួនបានប្រើប្រាស់គ្រឿងញៀនរយៈពេល២ខែមកហើយ និងទិញគ្រឿងញៀនពីឈ្មោះ[redacted]វណ្ណនី ហៅ ម៉ោល បានចំនួន១៥ដងមកហើយ។ ដូច្នេះចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] ណាភ៉ត់ ហៅ វិត មានភាពស៊ីសង្វាក់ជាមួយកំណត់ហេតុកំណត់ហេតុទទួលចាប់យក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងនានាបញ្ជាក់ថា: ជនជាប់ចោទឈ្មោះឈ្មោះ[redacted]វណ្ណី ហៅ ម៉ោល ពិតជាបានធ្វើការលក់គ្រឿងញៀនឱ្យជនជាប់ចោទឈ្មោះកែវ ណាភ៉ត់ ហៅ វិត នាថ្ងៃកើតហេតុប្រាកដមែន។ ផ្ទុយទៅវិញតាមចម្លើយរបស់ជនជាប់ចោទឈ្មោះកែវ ណាភ៉ត់ ហៅ វិត មានភាពស៊ីសង្វាក់ជាមួយភស្តុតាងនានា បញ្ជាក់ថា: អំពើល្មើសរបស់ជនជាប់ចោទឈ្មោះ[redacted] ណាភ៉ត់ ហៅ វិត មានធាតុផ្សំជាបទល្មើស: រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។ គប្បី កែប្រែបទចោទ ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ: រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលត្រូវផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

៣-កំណត់ហេតុទទួលចាប់យក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់មន្ត្រីនគរបាលយុត្តិធម៌។ គប្បី តុលាការពិចារណា។

៤-កំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់សារធាតុញៀន ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀន បានដកយកសំណាកសារធាតុមានគំរុយថា ជាគ្រឿងញៀនខុសច្បាប់ដែលមានចំនួនសរុបទម្ងន់០,១១ក្រាម របស់ឈ្មោះ[redacted] ណារ៉ាត់ ហៅ វិត។

៥-លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ១៤៧២៣/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសន្និដ្ឋានថា:សំណាកជាគ្រឿងញៀន ប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ ៨០,៨៦ ភាគរយនៃទម្ងន់សរុប របស់ឈ្មោះ[redacted] ណារ៉ាត់ ហៅ វិត។ ដូច្នេះ សារធាតុគ្រឿងញៀនមានបរិមាណធាតុសុទ្ធ គឺ $\frac{0,11g \times 80,86\%}{100} =$ 0,088 ក្រាម។

៦-តំណាងអយ្យការប្តឹងសុំកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះកែវ ណារ៉ាត់ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។ ការប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវគប្បីតុលាការសម្រេចតាមការប្តឹងសុំនេះ។

៧-ចម្លើយជនជាប់ចោទ និងភស្តុតាងនានាមានភាពស៊ីសង្វាក់ដែលដាក់បន្ទុកលើជនជាប់ចោទឈ្មោះកែវ ណារ៉ាត់ ហៅ វិត ពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងជនជាប់ចោទឈ្មោះ[redacted] វណ្ណនី ហៅ ង៉ោល ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិឈើទាលភ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] ណារ៉ាត់ ហៅ វិត ពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងជនជាប់ចោទឈ្មោះ[redacted] វណ្ណនី ហៅ ង៉ោល ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិឈើទាលភ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨។

៩-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៧៩ "ចខ" ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ លើឈ្មោះ[redacted] វណ្ណនី ហៅ ង៉ោល ភេទប្រុស អាយុ ៣៣ឆ្នាំ។ គប្បី តុលាការបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទ ដើម្បីបញ្ចប់បទល្មើស និងធានាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

១០-ជនជាប់ចោទមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួន និងចំពោះមុខច្បាប់។

១១-សកម្មភាពល្មើសរបស់ជនជាប់ចោទ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម។

១២-ជនជាប់ចោទឈ្មោះ[redacted] វណ្ណនីហៅង៉ោល ជាអ្នកទិញលក់គ្រឿងញៀនខុសច្បាប់យ៉ាងសកម្ម។ រីឯជនជាប់ចោទឈ្មោះ[redacted] ណារ៉ាត់ ហៅ វិត ជាអ្នករក្សាទុកគ្រឿងញៀនដោយខុសច្បាប់។ គប្បីតុលាការពិចារណាលើការផ្តន្ទាទោស។

១៣-ជនជាប់ចោទខ្វះការពិចារណាបណ្តាលឱ្យជម្រុញប្រព្រឹត្តបទល្មើស។

## ហេតុដូច្នេះសម្រេច

**១**-កែប្រែបទចោទលើឈ្មោះ[redacted] **ណារ៉ាត់** ហៅ **វិត** ភេទប្រុស អាយុ ២៥ឆ្នាំ ពីបទៈ**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលត្រូវផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទៈ**រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលត្រូវផ្តន្ទា



Scanned with CamScanner

ទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ផ្តន្ទាទោសលើៈ

**ក**-ឈ្មោះ [redacted] **ណារ៉ាត់** ហៅ **វិត** ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤(បួន)លានរៀល។

ពីបទៈ**រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិឈើទាលភ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**ខ**-ឈ្មោះ [redacted] **វណ្ណារី** ហៅ **ខ៊ោល** ភេទប្រុស អាយុ ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ និង៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ចំនួន ៥(ប្រាំ)លានរៀល។

ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិឈើទាលភ្លោះ ឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៨។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-រឹបអូសវត្ថុតាងយក ទុកៈ ស្រោមសំបុត្រពណ៌ស មានផ្តិតខ្មៅដៃជនសង្ស័យឈ្មោះ[illegible] ណារ៉ាត់ ហៅវិតនិងចុះហត្ថលេខាអ្នកចូលរួមពេលបើកស្រោម ... ពណ៌លឿងទុំទៅពណ៌ត្នោត សង្ស័យថាជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីនចំនួន 0,11g(សូន្យក្បៀសដប់មួយក្រាម)។

៤-បង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនឈ្មោះ [redacted] **វណ្ណារី** ហៅ **ខ៊ោល** ភេទប្រុស អាយុ ៣៣ឆ្នាំ យកមកឃុំខ្លួននៅពន្ធនាគារខេត្តក្រចេះ ដើម្បីឱ្យមកទទួលទណ្ឌកម្មតាមអំណាចសាលក្រមនេះ។ តាមមាត្រា៣៥៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] **ណារ៉ាត់** ហៅ**វិត** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **វណ្ណារី** ហៅ**ខ៊ោល** ។ ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និងត្រា: [redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខា និងត្រា: [redacted]

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម**
**ថ្ងៃ........ ខែ........ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២**
**ធ្វើនៅក្រចេះ ថ្ងៃទី...16... ខែមករា ឆ្នាំ២០១៩**
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner